ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៨២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលមាត្រា៣ នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ស្តីពីការកំណត់ និងការបែងចែកតំបន់គ្រប់គ្រង ក្នុងឧទ្យានជាតិសមុទ្រព្រះសីហនុរាម ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ស្តីពីការកែប្រែតំបន់ការពារធម្មជាតិពីឧទ្យានជាតិព្រះសីហនុ«រាម» ទៅជាឧទ្យានជាតិសមុទ្រព្រះសីហនុរាម
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ស្តីពីការកំណត់ និងការបែង ចែកតំបន់គ្រប់គ្រងក្នុងឧទ្យានជាតិសមុទ្រព្រះសីហនុរាម
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ ស្តីពីការកាត់ឆ្វៀលដីទំហំ ៩៣ហិកតា និង៦៣អា ចេញពីតំបន់ប្រើប្រាស់ដោយចីរភាពនៃឧទ្យានជាតិសមុទ្រព្រះសីហនុរាមកំណត់ ដោយអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០៨ ស្ថិតនៅ ភូមិអុងឃុំរាម ស្រុក ព្រៃនប់ ខេត្តព្រះសីហនុ ផ្តល់សិទ្ធិជាកម្មសិទ្ធិជូន អ្នកឧកញ៉ា យុន សៀ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការកែប្រែតំបន់ប្រើប្រាស់ដោយចីរភាពក្នុងឧទ្យានជាតិសមុទ្រព្រះសីហនុរាម មកជាតំបន់សហគមន៍
- បានឃើញអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការកំណត់តំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សម្រេច**

**មាត្រាមួយ.-**

ត្រូវបានកែសម្រួលមាត្រា៣ នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ស្តីពីការកំណត់ និងការបែងចែកតំបន់គ្រប់គ្រង ក្នុងឧទ្យានជាតិសមុទ្រព្រះសីហនុរាម ដូចតទៅ៖

**មាត្រា៣.- ថ្មី**

ត្រូវបានបែងចែកតំបន់គ្រប់គ្រងក្នុងឧទ្យានជាតិសមុទ្រព្រះសីហនុរាម ជា ២(ពីរ) តំបន់ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១ និងនិយាមកាភ្ជាប់ក្នុងឧបសម្ព័ន្ធ២ រួមមាន៖

**១. តំបន់ប្រើប្រាស់ដោយចីរភាព** មានផ្ទៃដីសរុបទំហំ **១១០៩០ (មួយម៉ឺនមួយពាន់កៅសិប) ហិកតា**។ តំបន់ប្រើប្រាស់ដោយចីរភាពត្រូវបានរៀបចំ និងគ្រប់គ្រងដោយក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តព្រះសីហនុ និងខេត្តកំពត ដោយគោរពតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិជាធរមាន។

**២. តំបន់សហគមន៍** មានផ្ទៃដីសរុបទំហំ **៨២៥៧ (ប្រាំបីពាន់ពីររយហាសិបប្រាំពីរ)ហិកតា**។ តំបន់សហគមន៍ត្រូវបានរៀបចំ និងគ្រប់គ្រងដោយក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តព្រះសីហនុ ដោយគោរពតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិជាធរមាន។ រាល់ការចេញប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី នៅក្នុងតំបន់សហគមន៍ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃពុធ ៨ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ